# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ទស្សនៈផ្ទាល់ខ្លួនចំពោះរបបខ្មែរក្រហម

នាងខ្ញុំឈ្មោះ ហ៊ឹម ស្វាមីយ៉ានី ភេទស្រី រៀននៅសកលវិទ្យាល័យអាស៊ាន ជំនាន់ទី២ ជំនាញហិរញ្ញវត្ថុនិងធនាគារ ។ ខ្ញុំកើតនៅភូមិប្រាំងចំរេះ សង្កាត់ប្រាំងចំរេះ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ សព្វថ្ងៃនេះខ្ញុំរស់នៅភូមិខាងលើ ។

ខ្មែរក្រហមបានធ្វើឲ្យប្រជារាស្ត្រខ្មែរគ្រប់រូបមានភាពឈឺចាប់ខ្លោចផ្សាក្រៃលែងនូវរាល់អតីតកាលដែលបានកើតឡើងកន្លងមកនោះ ។ វាបានធ្វើឲ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះដុនដាបយ៉ាងខ្លាំងរហូតមកទល់ពេលនេះ ក៏នៅពុំទាន់បានរីកចម្រើនខ្លាំងដូចសម័យសង្គមរាស្ត្រនិយមនៅឡើយ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រជារាស្ត្រខ្មែរមានសន្តិភាពប្រសើរជាងរបបខ្មែរក្រហមដែលមានតែភាពជិះជាន់គាបសង្កត់ទាំងផ្លូវកាយនិងផ្លូវចិត្ត គ្មានសេរីភាពនាសម័យនោះ ។

តើមានប្រតិកម្មយ៉ាងណាខ្លះបន្ទាប់ពីបានឮនូវអតីតកាលរបស់ឪពុកម្តាយជីដូនជីតានាសម័យនោះលើយុវសិស្សទាំងអស់នៅជំនាន់ក្រោយនេះ?

ជាការពិតណាស់នៅបណ្តាប្រទេសទូទាំងពិភពលោក ពួកគេរមែងចង់បាននូវសេរីភាពសុខសន្តិភាព នៅក្នុងសង្គមរស់នៅរបស់ខ្លួនប្រកបដោយសុខក្សេមក្សាន្តគ្មានសង្គ្រាម ។ ថ្វីដ្បិតតែដូច្នោះក៏ដោយបញ្ហាទាំងនេះនៅតែកើតមានឡើងរាល់បណ្តាប្រទេសមួយចំនួនលើពិភពលោក ក្នុងនោះរួមទាំងប្រទេសកម្ពុជាផងដែរ បានជួបនូវវិបត្តិសង្គ្រាមនៅរបបប្រល័យពូជសាសន៍ប៉ុលពតខ្មែរក្រហមនេះ ។ វាជាអំពើមនុស្សឃាតដែលពិភពលោកស្អប់ខ្ពើមបំផុត ។ នៅក្នុងរបបនេះដែរ អ្នកម៉ាក់របស់នាងខ្ញុំឈ្មោះ ស្នាន សហ៊ីយ៉ាស់ នាសម័យនោះមានអាយុ១៥ឆ្នាំ ។ គាត់ជាក្មេងកំព្រាម្តាយតាំងពីគាត់កើតបានអាយុមួយថ្ងៃ ។ គាត់បានរស់នៅជាមួយជីដូននិងមីងមារបស់គាត់ដែលរ៉ាប់រងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចមករហូត ។ គាត់មានឪពុកប៉ុន្តែដូចជាគ្មានអ៊ីចឹងដែរ ពីព្រោះឪពុកគាត់មានគ្រួសារ (ប្រពន្ធ) ផ្សេងទៀត ហើយគាត់កំព្រានៅជំនាន់នោះ មានភាពលំបាកលំបិនយ៉ាងខ្លាំង ។ គាត់ហូបចុកមិនគ្រប់គ្រាន់ ធ្វើការហួសកម្លាំង គាត់មានបញ្ហាភ្នែកខ្វាក់មានទៀត ។ នៅពេលគាត់រៀបរាប់ពីដំណើរជីវិតដ៏ល្វីងជូរចត់របស់គាត់នាសម័យនោះ បានធ្វើឲ្យគាត់រលីងរលោងស្ទើរស្រក់ទឹកភ្នែក ហើយក៏បានធ្វើឲ្យខ្ញុំស្ទើរទប់ទឹកភ្នែកមិនបានជាមួយគាត់ដែរ ។ នាពេលនោះគាត់រស់នៅជាមួយជីដូននិងមីងមារបស់គាត់លោកយាយគាត់ថ្ងៃណាក៏យំបង្ហូរទឹកភ្នែកដែរ ពីព្រោះតែគាត់អាណិតចៅក្នុងចិត្តខ្លោចផ្សាជាពន់ពេក ។ មួយសប្តាហ៍គេបើកអង្ករឲ្យមួយកំប៉ុងអំបិលមួយស្លាបព្រាបាយប៉ុណ្ណោះ ធ្វើការរហូតទល់យប់ គេឲ្យកាប់ដី៤ម៉ែត្រគីបក្នុង១ថ្ងៃ ហើយនៅឆ្ងាយៗពីកន្លែងខ្ទមស្នាក់នៅទៀត ។ អ្នកម៉ាក់របស់នាងខ្ញុំបាន

និយាយទៀតថា ពេលយប់គាត់ដើរមើលពុំសូវច្បាស់ដោយសារតែគាត់ខ្វាក់មាន់ បានធ្វើឲ្យគាត់ធ្លាក់រណ្ដៅដីធំៗ ស្ទើរស្លាប់ស្ទើររស់ ។ ពេលខ្លះត្រូវគេភ្ជង់គំរាមសម្លាប់ក៏មាន ។ ទន្ទឹមនឹងនោះដែរ គាត់តែងតែពោលថា គាត់មានអាយុវែងនេះដោយសារព្រះជាម្ចាស់ប្រទានឲ្យគាត់ទេ ។ គាត់ជាមនុស្សរស់ពីសេចក្ដីស្លាប់កាលពីជំនាន់នោះប៉ុណ្ណោះ ។ បងប្អូនជីដូនជីតារបស់គាត់បានស្លាប់នៅរបបប្រល័យពូជសាសន៍ខ្មែរក្រហមនោះអស់មួយចំនួនធំ ។ ខ្លះស្លាប់ដោយអត់បាយ ខ្លះស្លាប់ដោយសារជំងឺ និងខ្លះទៀតត្រូវបានគេសម្លាប់យ៉ាងឃោរឃៅព្រៃផ្សៃ យង់ឃ្នងជាទីបំផុត ។ ចំពោះគាត់វិញ ត្រូវបានគេជម្លៀសពីកន្លែងមួយទៅកន្លែងជាច្រើនស្ទើររាប់មិនអស់ រហូតទាល់តែប្រទេសមានសន្តិភាពវិញទើបបានមករស់នៅក្រុងភ្នំពេញវិញ ។ តស៊ូគង់បានសម្រេច ។

បន្ទាប់ពីបានស្ដាប់អំពីជីវិតតស៊ូយ៉ាងលំបាកវេទនារួមទាំងនាងខ្ញុំបានឃើញនូវឧបករណ៍ធ្វើទារុណកម្មផ្សេងៗនៅក្នុងគុកទួលស្លែងនិងទីតាំងរណ្ដៅផ្សេងទៀតជាច្រើននៅជើងឯកបានធ្វើឲ្យនាងខ្ញុំមានអារម្មណ៍ក្ដុកក្ដួលសង្វេគខ្លោចផ្សាក្រៃលែងដែលគាត់បានរស់រានមានជីវិតជម្នះបាននូវភាពជូរចត់យ៉ាងខ្លាំងបែបនេះ ។ ទន្ទឹមនឹងនេះដែរ ក៏អាចនិយាយបានថា វាជាសំណាងខ្លាំងណាស់ហើយចំពោះអ្នកដែលកើតមិនទាន់របបនោះ ។ តួយ៉ាងដូចជារូបនាងខ្ញុំរួមទាំងអ្នកដទៃទៀតដែលរួចផុតពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមនាសម័យកាលនោះ ។

ចំពោះទស្សនៈផ្ទាល់របស់នាងខ្ញុំ ខ្ញុំគិតថាក៏មិនខុសពីយុវសិស្សដទៃទៀតដែរទៅលើបញ្ហាដែលបានកើតឡើង វាជាអំពើមនុស្សឃាតដ៏ព្រៃផ្សៃគួរឲ្យស្អប់ជាទីបំផុត ។ នាងខ្ញុំសូមប្រាថ្នាកុំឲ្យជួបនូវបញ្ហាទាំងនោះទៀត ។ សុំឲ្យប្រទេសជាតិជួបតែភាពសុខសាន្តត្រានតរៀងទៅ ។ ម្យ៉ាងវិញទៀត ប្រទេសជាតិរីកចម្រើនទៅបានក៏ដោយសារកម្លាំងរួបរួមសាមគ្គីភាតរភាពរស់ដោយសន្តិភាពមិនបៀតបៀនគ្នាបេះសណ្ដោសប្រណីឲ្យគ្នាទៅវិញទៅមក រស់នៅក្រោមម្លប់មាគ៌ាដ៏ត្រចះត្រចង់ផ្លូវផងទៅតាមការដឹកនាំប្រទេសដោយឧត្ដមគតិមោះមុត ភាពឆ្លាតវៃដ៏ឆ្នើមដែលជាមគ្គុទេសតម្រង់ផ្លូវឲ្យឈានទៅរកជោគជ័យសុខសន្តិភាពជូនប្រជាជាតិរបស់ខ្លួន ។ បន្ថែមលើនេះទៅទៀតគឺថានាពេលបច្ចុប្បន្ននេះសម្បូរទៅដោយអ្នកមានចំណេះវិជ្ជាខ្ពង់ខ្ពស់ជាកម្លាំងចលករយ៉ាងពិសិដ្ឋ ជាធនធានមនុស្សដ៏សម្បូរបែបដែលមានទាំងគំនិតនិងប្រាជ្ញាបច្ចេកវិជ្ជាទំនើប មានសម្ភារប្រើប្រាស់ផ្សេងៗដែលបានរួមចំណែកពន្លឿនការអភិវឌ្ឍកសាងនិងស្ដារឡើងវិញឲ្យកាន់តែប្រសើរឡើងថែមទៀត ។ សេដ្ឋកិច្ចជាតិរីកចម្រើនប្រទេសសម្បូរសប្បាយ ។

ជាទីបញ្ចប់នេះ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ខ្មែរក្រហមនេះកុំឲ្យកើតមានម្តងទៀត យើងទាំងអស់គ្នាគួរគប្បីត្រូវបេះរួមគំនិតគ្នាកសាងលទ្ធិប្រជាធិបតេយ្យគោរពសិទ្ធិគ្នា រួមកម្លាំងជាស្ពានឈានទៅរកក្តីសុខ បំបាត់អសីលធម៌និងអំពើអមនុស្សធម៌ចោលឲ្យអស់ដើម្បីជីវិតថ្ងៃថ្លាទៅអនាគត ។